# ព្រះរាជក្រឹត្យ

នស/រកត/១២២៣/៤៥៦៤

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា**ក.អ.ក.**។

## ជំពូកទី២

## បេសកកម្ម មុខងារ និងភារកិច្ចរបស់ក.អ.ក.

**មាត្រា២ .-**

**ក.អ.ក.** ជាស្ថាប័នប្រតិបត្តិ បំពេញមុខងារជាសេនាធិការនិងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំនិងគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា៣ .-**

**ក.អ.ក.** មានភារកិច្ចដូចខាងក្រោមៈ

- រៀបចំសេចក្ដីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការសកម្មភាពដើម្បីជំរុញការងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ស្របតាមបរិយាការណ៍ក្នុងតំបន់និងសកលលោក
- រៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រនិងវិធានការជាក់ស្ដែង រយៈពេលខ្លី មធ្យម និងវែងសម្រាប់ធ្វើជាផែនទីចង្អុលផ្លូវក្នុងការជំរុញនិងទាក់ទាញការវិនិយោគឯកជន ទាំងក្នុងនិងក្រៅប្រទេស
- អនុវត្តការងារសម្របសម្រួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយវិនិយោគិន ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការពាក់ព័ន្ធនានាឱ្យមានប្រសិទ្ធភាព
- ទាក់ទងជាមួយដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រនិងបណ្ដាកម្មវិធីអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេស ដើម្បីសម្របសម្រួលការទទួលនិងការប្រើប្រាស់ប្រកបដោយសក្ដិសិទ្ធិភាព នូវហិរញ្ញប្បទានសហប្រតិបត្តិការ ស្របតាមតម្រូវការនិងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ
- ពិនិត្យនិងផ្ដល់ការគាំទ្រដល់គម្រោងរបស់ដៃគូអភិវឌ្ឍ
- កំណត់ទិសដៅក្នុងការបែងចែកនិងប្រើប្រាស់ធនធានសាធារណៈនិងធនធានឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា
- ផ្ដល់កិច្ចសម្រួលដល់ដៃគូអភិវឌ្ឍ
- ពិនិត្យនិងសម្រេចរាល់គម្រោងវិនិយោគឯកជន គម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងគម្រោងរបស់ដៃគូអភិវឌ្ឍ

- ជំរុញការផ្សព្វផ្សាយនិងការទាក់ទាញការវិនិយោគ ដោយផ្ដោតលើវិស័យនិងសកម្មភាពវិនិយោគជាអាទិភាព ដូចមានចែងក្នុងច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមការតម្រង់ទិសពីប្រមុខរាជរដ្ឋាភិបាល
- ជំរុញលើកទឹកចិត្តនិងការពារការវិនិយោគឯកជននិងផ្ដល់កិច្ចសម្រួលដល់វិនិយោគិន
- ផ្ដល់សេវាថែទាំវិនិយោគដោយផ្អែកលើឧត្ដមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការវិនិយោគ
- ជំរុញការបង្កើតតម្រង់ឧស្សាហកម្ម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពយន្ដការតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាអនុលោមភាពគតិយុត្តនិងលក្ខខណ្ឌនានា ដែលជាមូលដ្ឋានទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាគម្រោងវិនិយោគ
- ទទួលបន្ទុកដឹកនាំកិច្ចការចរចាកិច្ចព្រមព្រៀងស្ដីពីវិនិយោគទ្វេភាគី ពហុភាគី ក្នុងក្របខ័ណ្ឌតំបន់និងអន្ដរជាតិ
- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗនៅក្នុងក្របខ័ណ្ឌអាស៊ាន ស្របតាមគោលការណ៍និងការរៀបចំរបស់អាស៊ាន
- សម្របសម្រួលការងារសម្រាប់យន្ដការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៤ .-**

**ក.អ.ក.** ត្រូវទទួលខុសត្រូវចំពោះគណៈរដ្ឋមន្ត្រីអំពីសកម្មភាពរបស់ខ្លួន។

**ក.អ.ក.** ត្រូវសុំការសម្រេចពីគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិណាមួយដូចខាងក្រោម៖

១- គម្រោងមានវេទយិតភាពខាងនយោបាយ។

២- គម្រោងអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថាន។

៣- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង។

៤- គម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

## ជំពូកទី៣

## សមាសភាពរបស់ក.អ.ក.

**មាត្រា៥ .-**

**ក.អ.ក.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២- | ឥស្សរជនមួយរូបឬច្រើនរូប | អនុប្រធាន |
| ៣- | រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្ដរជាតិ | សមាជិក |

| | | |
|---|---|---|
| ៦- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៤- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១៥- | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៦- | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៧- | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៨- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៩- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ២០- | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២១- | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ២២- | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន | សមាជិក |
| ២៣- | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៤- | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ២៥- | អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ២៦- | អគ្គលេខាធិការនៃគណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៧- | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.** | លេខាធិការ។ |

ការតែងតាំងសមាសភាពជាក់ស្តែងនៃ**ក.អ.ក.** ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យដោយឡែក។

**ក.អ.ក.** អាចមានសមាសភាពបន្ថែមជារដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាលតាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ក.អ.ក.

**មាត្រា៦ .-**

**ក.អ.ក.** មានកិច្ចប្រជុំសាមញ្ញនិងវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធានឬអនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធាន**ក.អ.ក.**។

អនុប្រធាននិងសមាជិកត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញនេះ។ ក្នុងករណីមិនអាចចូលរួមបានត្រូវចាត់តំណាងនិងផ្តល់សិទ្ធិឱ្យតំណាងមានសិទ្ធិសម្រេចពេញលេញ សម្រាប់កិច្ចពិភាក្សានិងសម្រេច។

**មាត្រា៧ .-**

រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នផ្សេងទៀតនៃរាជរដ្ឋាភិបាលដែលមិនមែនជាសមាជិក**ក.អ.ក.** ត្រូវចូលរួមកិច្ចប្រជុំរបស់**ក.អ.ក.** តាមការអញ្ជើញរបស់ប្រធាន**ក.អ.ក.**។ រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នដែលផ្តល់សិទ្ធិឱ្យតំណាងរបស់ខ្លួនចូលរួម ត្រូវផ្តល់សិទ្ធិសម្រេចពេញលេញសម្រាប់ការពិភាក្សានិងការសម្រេច។

**មាត្រា៨ .-**

**ក.អ.ក.** មានសិទ្ធិប្រើត្រាដោយឡែក ដែលកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**ក.អ.ក.** សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ក.អ.ក.** មានសិទ្ធិប្រើសញ្ញាជាតិជារូបសញ្ញារបស់ខ្លួន។

**មាត្រា៩ .-**

**ក.អ.ក.** មាននាយករដ្ឋមន្ត្រីជាប្រធាន ព្រមទាំងមានអនុប្រធានមួយរូបឬច្រើនរូប និងសមាជិកមួយចំនួនតាមការចាំបាច់។

ប្រធាន**ក.អ.ក.** អាចប្រគល់សិទ្ធិដល់អនុប្រធានដែលជាសមាជិកនៃរាជរដ្ឋាភិបាល ដើម្បីដឹកនាំជំនួសក្នុងកម្រិតណាមួយឬក្នុងផ្នែកណាមួយនៃការងាររបស់**ក.អ.ក.** ក្នុងគោលដៅធានាប្រសិទ្ធភាព នៃការបំពេញបេសកកម្មដែលមានកំណត់ក្នុងមាត្រា៤នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលនូវការគ្រប់គ្រងនិងការចាត់ចែងប្រើប្រាស់ថវិកានិងធនធានមនុស្ស ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០ .-**

ការបែងចែកភារកិច្ចនិងរបៀបរបបការងាររបស់អនុប្រធាននិងសមាជិក**ក.អ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**ក.អ.ក.**។

**មាត្រា១១ .-**

**ក.អ.ក.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- អគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.**
- គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា**គ.ស.អ.ក.**
- គណៈកម្មាធិការវិនិយោគកម្ពុជា ដែលសរសេរជាអក្សរកាត់ថា**គ.វ.ក.**។

**ក.អ.ក.** អាចបង្កើតរចនាសម្ព័ន្ធឬយន្តការនានាបន្ថែមទៀត តាមការចាំបាច់ដោយអនុក្រឹត្យ។

អង្គការលេខនៃរចនាសម្ព័ន្ធ**ក.អ.ក.** ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

**មាត្រា១២ .-**

អគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.** **គ.ស.អ.ក.** និង**គ.វ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបរៀងៗខ្លួន អមដោយអគ្គលេខាធិការរងមួយចំនួនសម្រាប់ជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.** អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃ**គ.ស.អ.ក.** និងអគ្គលេខាធិការនិងអគ្គលេខាធិការរងនៃ**គ.ឋ.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**មាត្រា១៣ .-**

អគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.** **គ.ស.អ.ក.** និង**គ.ឋ.ក.** មានអង្គភាពថ្នាក់នាយកដ្ឋានមួយចំនួនជាសេនាធិការ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.** **គ.ស.អ.ក.** និង**គ.ឋ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**ក.អ.ក.** អាចមានទីប្រឹក្សានិងជំនួយការមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៤ .-**

**ក.អ.ក.** មានមន្ត្រីរាជការក្របខ័ណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥

## ភារកិច្ចរបស់រចនាសម្ព័ន្ធនីមួយៗនៃក.អ.ក.

### ផ្នែកទី១

### អគ្គលេខាធិការដ្ឋាននៃក.អ.ក.

**មាត្រា១៥ .-**

អគ្គលេខាធិការដ្ឋាននៃ**ក.អ.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាលនិងសម្របសម្រួលសកម្មភាពទាំងឡាយរបស់**ក.អ.ក.**
- ផ្តល់សេវាគាំទ្រនិងបំពេញការងារចាំបាច់សម្រាប់ប្រក្រតីភាពនៃដំណើរការរបស់**ក.អ.ក.**
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ជួយគាំទ្រដល់ការគ្រប់គ្រងរបស់**ក.អ.ក.**
- សម្របសម្រួលកិច្ចទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយព័ត៌មានរបស់**ក.អ.ក.**
- រៀបចំ គ្រប់គ្រង និងចាត់ចែងថវិការបស់**ក.អ.ក.**
- គ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់**ក.អ.ក.**
- គ្រប់គ្រងធនធានមនុស្ស សម្របសម្រួលការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និងការរៀបចំអនុវត្តផែនការបណ្តុះបណ្តាលនិងវិក្រឹត្យការ
- គ្រប់គ្រងនិងថែទាំចលនទ្រព្យ អចលនទ្រព្យ រួមទាំងអគារទីស្តីការ**ក.អ.ក.**
- គ្រប់គ្រងការងារលទ្ធកម្ម ទទួលនិងបែងចែកសម្ភារៈបរិក្ខារដល់គ្រប់អង្គភាពចំណុះ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងដែនសមត្ថកិច្ចរបស់**ក.អ.ក.**
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធានឬអនុប្រធាន**ក.អ.ក.**។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី២

## គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា(គ.ស.អ.ក.)

**មាត្រា១៦ .-**

**គ.ស.អ.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- បំពេញតួនាទីជាច្រកចេញចូលតែមួយ ក្នុងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ហិរញ្ញប្បទានឥតសំណងដល់កម្ពុជា និងជាចំណុចប្រមូលផ្តុំក្នុងទំនាក់ទំនងរវាងក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួល និង/ឬគ្រប់គ្រងហិរញ្ញប្បទានទាំងនេះ
- រៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ដើម្បីពង្រឹងភាពជាម្ចាស់និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ក៏ដូចជាពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍ
- ពិភាក្សាជាមួយដៃគូអភិវឌ្ឍ ដើម្បីរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី
- កៀរគរនិងតម្រង់ទិសការវិភាជហិរញ្ញប្បទានសហប្រតិបត្តិការ និងគ្រប់គ្រងការប្រើប្រាស់ធនធានទាំងនេះឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ក្នុងការរួមចំណែកអនុវត្តឱ្យបានសម្រេចនូវគោលដៅអាទិភាពដែលមានចែងក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ
- ដឹកនាំការធ្វើសុខដុមនីយកម្មនៃការអនុវត្តរបស់ដៃគូអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ
- ដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំឬកិច្ចពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍ ដើម្បីពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍
- រៀបចំ សម្របសម្រួល និង/ឬផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់យន្តការពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងតាមវិស័យ ក៏ដូចជាតាមដានការអនុវត្ត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពយន្តការទាំងនេះ
- ចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចពិគ្រោះយោបល់និងចុះហត្ថលេខា លើកម្មវិធីសហប្រតិបត្តិការទ្វេភាគីជាមួយដៃគូអភិវឌ្ឍ
- ផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត លើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងឬកម្មវិធីដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល
- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចកម្ពុជា ផែនការអភិវឌ្ឍន៍តាមវិស័យ និងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមនិងអនុវត្តយន្តការអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសក្តិសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនិងភាពជាដៃគូសកល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- គ្រប់គ្រងនិងតាមដានលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈការរៀបចំ ការពង្រឹង និងការធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ
- រៀបចំរបាយការណ៍វាយតម្លៃស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនិងភាពជាដៃគូ រួមទាំងលើកសំណើវិធានការគោលនយោបាយសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃហិរញ្ញប្បទានទាំងនេះ
- ដឹកនាំអង្គប្រជុំច្រកចេញចូលតែមួយ ដើម្បីពិនិត្យនិងដោះស្រាយសំណើសុំអនុញ្ញាតនាំចូលឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផលតេលសិលា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធានឬអនុប្រធាន**ក.អ.ក.**។

## ផ្នែកទី៣

## គណៈកម្មាធិការវិនិយោគកម្ពុជា(គ.វ.ក.)

**មាត្រា១៧ .-**

**គ.វ.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- បំពេញតួនាទីជាច្រកចេញចូលតែមួយ ក្នុងការពិនិត្យ វិភាគ និងលើកយោបល់លើគម្រោងវិនិយោគនានានិងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជូនថ្នាក់ដឹកនាំ**ក.អ.ក.** ដើម្បីពិនិត្យនិងសម្រេច
- ពិនិត្យនិងសម្រេចលើសំណើនានាពាក់ព័ន្ធនឹងការអនុវត្តគម្រោងវិនិយោគ
- ត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគតាមបណ្តាកោះ ឆ្នេរ និងបណ្តាទីតាំងវិនិយោគនានា ដែល**ក.អ.ក.** បានចុះកិច្ចសន្យាជួលឬសម្បទានណាមួយក្នុងនាមរាជរដ្ឋាភិបាល ជាមួយផ្នែកឯកជន រួមទាំងការតាមទារថ្លៃឈ្នួល ដើម្បីរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ**ក.អ.ក.** ពិនិត្យនិងសម្រេច
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ លើកគម្រោងផែនការ និងកំណត់ទិសដៅសម្រាប់ការវិនិយោគឯកជន និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំចងក្រងឯកសារនិងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធនឹងកិច្ចការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ផ្សព្វផ្សាយនិងជំរុញការវិនិយោគទាំងក្នុងប្រទេសនិងក្រៅប្រទេស
- ផ្តល់សេវានិងកិច្ចសម្រួលវិនិយោគ ដោយធានានូវប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពជូនវិនិយោគិនជាពិសេស តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យា
- ពិនិត្យនិងតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងក្នុងករណីចាំបាច់ លើកសំណើកែសម្រួលក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះនិងលើកទឹកចិត្តដល់វិនិយោគិន ក្នុងទិសដៅបង្កើនប្រសិទ្ធភាព ផ្តល់សេវាសម្របសម្រួល និងថែទាំវិនិយោគទាំងក្នុងនិងក្រៅតំបន់សេដ្ឋកិច្ចពិសេស

- ធ្វើការផ្សព្វផ្សាយអំពីគម្រោងវិនិយោគសម្រាប់ការវិនិយោគឯកជននិងតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើងនិងផ្តល់គម្រោងទាំងនោះទៅឱ្យវិនិយោគិន ដោយអនុលោមតាមច្បាប់និងនីតិវិធីជាធរមាន
- កំណត់គោលការណ៍និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធដល់ការងារតែងតាំងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ការចាត់តាំងយន្តការច្រកចេញចូលតែមួយនៅក្នុងតំបន់ ការគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅនៃដំណើរការរបស់តំបន់ និងការដោះស្រាយបញ្ហាផ្សេងៗ ជាយថាហេតុ
- អនុវត្តផ្តល់ការលើកទឹកចិត្តដល់វិនិយោគិន ក៏ដូចជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងផ្តល់ការណែនាំគោលការណ៍នៃការលើកទឹកចិត្តរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ផ្តល់ជូនដល់វិនិយោគិនក្នុងតំបន់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំគោលការណ៍ណែនាំអំពីការងារគ្រប់គ្រងនិងការបណ្តុះបណ្តាលកម្មករ និយោជិត ការងារបរិស្ថាន ការនាំចេញនាំចូល ការទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងកិច្ចការជំនាញផ្សេងៗទៀត រួមទាំងការបង្កលក្ខណៈងាយស្រួលក្នុងកិច្ចទំនាក់ទំនងជាមួយក្រសួង ស្ថាប័ននានា
- ដោះស្រាយរាល់សំណូមពរពាក់ព័ន្ធនឹងផលប្រយោជន៍របស់អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស វិនិយោគិនក្នុងតំបន់ កម្មករ និយោជិត និយោជក និងបណ្តាសំណូមពរផ្សេងៗ
- លើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជននិងតំបន់សេដ្ឋកិច្ចពិសេស
- ធ្វើការវិភាគឧត្តមភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជននិងតំបន់សេដ្ឋកិច្ចពិសេស
- ទទួលបន្ទុកការងារតំបន់វិនិយោគអាស៊ាន ដោយសម្របសម្រួល ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធានឬអនុប្រធាន**ក.អ.ក.**។

## ជំពូកទី៦

## ប្រភពធនធានរបស់ក.អ.ក.

**មាត្រា១៨ .-**

**ក.អ.ក.** មានថវិកាដោយឡែកជាថវិកាជាតិសម្រាប់ដំណើរការការងារ។ ការគ្រប់គ្រងនិងការចាត់ចែងប្រើប្រាស់ថវិការបស់**ក.អ.ក.** ត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា១៩ .-**

មន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ក្រសួង ស្ថាប័នផ្សេង ហើយដែលកំពុងបម្រើការងារនៅ**ក.អ.ក.** ត្រូវផ្ទេរមាហរណកម្មមកក្នុងក្របខ័ណ្ឌ**ក.អ.ក.** តាមការស្ម័គ្រចិត្ត ដោយការផ្ទេរផ្តាច់ក្របខ័ណ្ឌពីក្រសួង ស្ថាប័នដើមរបស់ខ្លួន។

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងជាធរមាន និងយន្តការការងារនានាដែលស្ថិតក្រោមអានុភាពនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា២០ .-**

អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៦រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០២៣

នសីហមុនី

**នរោត្តម សីហមុនី**

ពរាប.២៣១៤.២៦៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ ៤៥៦៤ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០២៣

ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក.អ.ក.**

